# ពាក្យ «ស្វាង» មិនមានប្រភពមកពីសៀមទេ

## ១- ព័ត៌មានទូទៅ

ពាក្យ «ស្វាង» មានប្រើប្រាស់នៅក្នុងភាសាខ្មែរ ភាសាថៃ ( សវ៉ាង สว่าง) និងភាសាលាវ (សៈហ្វាង ສະຫວ່າງ)។ ពាក្យនេះមានប្រើក្នុងនាមខត្តិយវង្សក្នុងភាសាលាវ ដូចជា **ព្រះចៅមហាជីវិតស្រីស្វាងវឌ្ឍនា** (ພະເຈົ້າມະຫາຊີວິດສີສະຫວ່າງວັດທະນາ) ជាអង្គមហាក្សត្រលាវចុងក្រោយជាដើម។ នៅក្នុងវចនានុក្រមខ្មែរ ចេញផ្សាយគ្រាទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ពន្យល់ប្រភព ពាក្យ «**ស្វាង**» ថាមកពីភាសាសៀម «**សវ៉ាង**» (អានថា សៈវ៉ាង)[១]។ ចំណែកឯវចនានុក្រមខ្មែរ ចេញផ្សាយដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ ចែកពាក្យ «ស្វាង» ជាមេពាក្យ២ផ្សេងគ្នា ដោយហាក់ដូចជាចាត់ទុកមេពាក្យទី១ ជាពាក្យខ្មែរ និងមេពាក្យទី២ ជាពាក្យមានប្រភពចេញពីភាសាសៀម[២] ដោយអនុលោមតាមវចនានុក្រមខ្មែរ ចេញផ្សាយដោយពុទ្ធសាសនបណ្ឌិត្យកន្លងមក។ រីឯវចនានុក្រមភាសាថៃ របស់រាជបណ្ឌិត្យស្ថាន[៣] វចនានុក្រមពាក្យកម្ចីភាសាខ្មែរក្នុងភាសាថៃ[៤] និងវចនានុក្រមភាសាឡាវ[៥] ពុំមានដាក់បញ្ជាក់ថាមានពាក្យនេះមានប្រភពមកភាសាខ្មែរឡើយ។ យ៉ាងនេះក្ដី ពាក្យនេះមានប្រទះឃើញក្នុងសិលាចារឹកខ្មែរតាំងពីសម័យមុនអង្គរមកម្ល៉េះ[៦]។

នៅក្នុងអត្ថបទនេះ នឹងលើកយកពាក្យ «ស្វាង» តាមរយៈតឹកតាងសិលាចារឹក និងទិដ្ឋភាពភាសាវិទ្យា ដើម្បីបញ្ជាក់ថា ពាក្យ «ស្វាង» ជាពាក្យខ្មែរ ពុំមានប្រភពមកពីភាសាសៀមនោះទេ។

---

[១] *វចនានុក្រមខ្មែរ*, ២ (ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨)។

[២] ក្រុមប្រឹក្សាជាតិភាសាខ្មែរ, *វចនានុក្រមខ្មែរ*, ក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា (ភ្នំពេញ, ២០២២)។

[៣] ‘พจนานุกรม ฉบับราชบัณฑิตยสถาน พ.ศ.๒๕๕๔’, accessed 29 November 2025, https://dictionary.orst.go.th/.

[៤] ศานติ ภักดีคำ, *พจนานุกรมคำยืมภาษาเขมรในภาษาไทย* (คณะกรรมการสมาคมวัฒนธรรมไทย-กัมพูชา กรมสารนิเทศ กระทรวงการต่างประเทศ, ๒๐๐๖).

[៥] ‘SEAlang Library Lao Lexicography’, accessed 29 November 2025, http://sealang.net/lao/dictionary.htm.

[៦] Philip N. Jenner, *A Dictionary of Pre-Angkorian Khmer* (The Australian National University, 2009); Pou Saveros, *Dictionnaire vieux khmer-français-anglais. An Old Khmer-French-English Dictionary. វចនានុក្រមខ្មែរចាស់-បារាំង-អង់គ្លេស* (L’harmattan, 2004); ឡុងសៀម, *វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរសតវត្សទី ៦-៨)* (ពេជពុម្ពភ្នំពេញ, ២០០០)។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## ២- អត្ថន័យពាក្យ

ពាក្យ «**ស្វាង**» មានថ្នាក់ពាក្យជាគុណនាម មានន័យដូចខាងក្រោម៖

- ភ្លឺ ភ្លឺស្រឡះ។ ឧ. ស្វាងឯកើត = ភ្លឺឯកើត (អរុណោទ័យ)[7]។
- ដែលអន់, ដែលធូរស្បើយ, ស្រាក។ ឧ. ស្វាងងងុយ, ស្វាងពីប្រកាច់, ស្វាងដឹង ស្រវឹងភ្លើ![៨]។

នៅក្នុងភាសាថៃ ពាក្យ «ស្វាង» ប្រើជាគុណនាមសំដៅដល់ ពេលព្រលឹមស្រាងៗ, ភ្លឺច្បាស់ល្អ មានពន្លឺច្រើន, ភ្លឺថ្លា (បញ្ញា), ភ្លឺ ច្បាស់ (ភ្នែក ត្រចៀក), អន់ងងុយ[៩]។ ឯក្នុងភាសាលាវ ក៏មានន័យប្រហាក់ប្រហែលគ្នានេះដែរ គឺប្រើជាគុណនាម មានន័យថា ដែលភ្លឺ ដែលមានពន្លឺ ដែលភ្លឺល្អ ដែលពេញដោយពន្លឺ និងប្រើជាកិរិយាសព្ទដែរ មានន័យថា ដល់ព្រលឹមស្រាងៗ ភ្លឺល្អ ពេញពន្លឺ[១០]។

យើងអាចសរុបន័យពាក្យ «ស្វាង» ទាំងក្នុងភាសាខ្មែរ ថៃ និងលាវ គឺទាក់ទងនឹងពន្លឺដែលចាប់ភ្លឺខ្លាំងទៅៗ។ ឯន័យថាអន់ ធូរស្បើយ ស្រាក ជាសមាសភាគន័យដែលទាក់ទងនឹងភាពផ្ទុយប្រាសពីងងឹត។ សភាពងងុយងោក ធ្វើឲ្យភ្នែកយើងមីរទន់ត្របកភ្នែកបិទភ្នែកម្ដងៗ ដែលនាំឲ្យភ្នែកមើលមិនច្បាស់ឬមិនឃើញ ពោលគឺងងឹត។ ស្វាងងងុយ គឺអារម្មណ៍ចាប់ផ្ដើមធូរស្រាល លែងទន់ភ្នែក ចាប់បើកភ្នែកមើលបានភ្លឺថ្លាជាងមុន។ល។

## ៣- ភស្តុតាងតាមរយៈសិលាចារឹក

បើពិនិត្យមើលនៅក្នុងសិលាចារឹកភាសាខ្មែរបុរាណ ពាក្យនេះមានវត្តមានតាំងពីសម័យមុនអង្គរនេះរួចទៅហើយ និងបន្តមានវត្តមាននៅសម័យអង្គរ ព្រមទាំងសម័យកណ្ដាលផងដែរ ដែលប្រើក្នុងន័យដូចបច្ចុប្បន្នផង និងប្រើជាឈ្មោះមនុស្សផង។ ដូច្នេះពាក្យនេះមានប្រើនៅក្នុងភាសាខ្មែរ តាំងពីដើមរៀងមកឥតដាច់នោះឡើយ។ នៅក្នុងសិលាចារឹកពាក្យនេះ មានសំណេរជា៖ **ស្វាង៑ សិវាង៑** និងមានពាក្យកម្ចាយជា **សង៑ហ្វង៑ សង៑ហ្វាង៑**។

---

[៧] វចនានុក្រមខ្មែរ, ២, ១៤៩៧។

[៨] ក្រុមប្រឹក្សាជាតិភាសាខ្មែរ, វចនានុក្រមខ្មែរ, ១៣៦៧។

[៩] ‘พจนานุกรม ฉบับราชบัณฑิตยสถาน พ.ศ.๒๕๕๔’.

[១០] ‘SEAlang Library Lao Lexicography’.

អត្ថបទដោយៈ ហ៊ុន ឈុនតេង

នៅក្នុងសិលាចារឹកត្រពាំងប្រី K.១២៧ ចុះកាលបរិច្ឆេទមហាសករាជឆ្នាំ ៦០៤ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៦២៨ ឬ ៦២៩ មានប្រភពមកពីស្រុកសំបូរ ខេត្តក្រចេះ ដែលល្បីល្បាញពីវត្តមានសញ្ញាលេខសូន្យដែលមានចំណាស់នោះ ក៏មានប្រើពាក្យនេះដែរ គឺនៅត្រង់បន្ទាត់ទី១១ ដូចមានក្នុងឃ្លាដកស្រង់នេះ៖ [...] **គិតស្វាងគិតជិវសញ្ចារស្ថិតដៅ** [...] ដែលសម្រួលជាភាសាខ្មែរទំនើបថា «គឺ(អ្នក)ដែលភ្លឺស្វាង(អ្នកអស់មន្ទិល អ្នកត្រាស់ដឹង) (គឺអ្នកនោះ)ទៅកាន់ស្ថានសួគ៌»[១១]។ ពាក្យ «ស្វាង» នៅក្នុងសិលាចារឹកខាងលើនេះ សំដៅដល់សេចក្តីអស់នូវមន្ទិលសៅហ្មង ភ្លឺយល់ច្បាស់នូវកុសលនិងអកុសលជាដើម។ យើងអាចយល់បានថា អកុសល បាបកម្មជាដើម គឺជាសេចក្តីខ្មៅងងឹត។ ដូច្នេះ អ្នកដែលស្វាង គឺអ្នកយល់ភ្លឺថ្លាច្បាស់នូវកុសលនិងអកុលជាដើម។

ចំណែកឯឈ្មោះមនុស្សវិញ មានសំណេរជា «ស្វាង៑» «សង៑ហ្វង៑»និង «សង៑ហ្វាង៑» ផង។ ឧ. «កុស្វាង៑» (K.៥២៦២ បន្ទាត់ទី១៩ ស.វ.៧) «កុសង៑ហ្វាង៑អញ្ជិទៃ» (K.៥៤ បន្ទាត់ទី១០ គ.ស.៦២៨) និង «សង៑ហ្វង៑» (K.៤៨០ បន្ទាត់ទី២ ស.វ.៧)។

នៅសម័យកណ្តាល ពាក្យនេះ នៅតែឃើញមានប្រើ ដូចជានៅក្នុងសិលាចារឹកសម័យកណ្តាលនៅប្រាសាទអង្គរវត្ត K.៣០២/IMA១៥ បន្ទាត់ទី១០ ដែលមានឃ្លាថា [...] **ប្រោសអាស្វូសនេះឱយរូចជាព្រៃស្វាងព្រះស្រលាះជ្រះឥតគាំម្តិងលេយ** [...] មានសេចក្តីជាភាសាខ្មែរទំនើបថា «...ប្រោសអាសួសនេះឱ្យរួចជាព្រៃស្វាងព្រះស្រឡះជ្រះឥតចំពាក់បំណុលគេទៀតឡើយ...»។ ក្នុងឃ្លានេះ ពាក្យ «ស្វាង ព្រះ ស្រឡះ ជ្រះ» សុទ្ធតែទាក់ទងជាមួយពន្លឺ ពុំជាប់ចំពាក់ជាមួយអ្វីទៀតឡើយ។ ពាក្យ «ព្រះ ស្រឡះ ជ្រះ» សុទ្ធតែកម្ចាយមកពីពាក្យឫស «រះ» ដែលសូមពុំអធិប្បាយនៅទីនេះឡើយ។ យ៉ាងណាក្តី ត្រឹមប៉ុណ្ណេះ ក៏យើងអាចឃើញបានថា ពាក្យនេះខ្មែរប្រើតាំងពីសម័យមុនអង្គររហូតមក។

## ៤- ឫស និងកម្លាយរបស់ពាក្យ «ស្វាង»

មុននឹងបន្តទៅដល់ឫសនិងកម្លាយរបស់ពាក្យ «ស្វាង» គួរយល់បន្តិចជាមុនថា ដ្បិតតែពាក្យនេះមានប្រើតាំងពីសម័យមុនអង្គរមក នោះពាក្យនេះមានការប្រែប្រួលសូរនិងន័យខ្លះៗជាក់ជាពុំខាន។ ជាធម្មតា ភាសារមែងមានការប្រែប្រួលគ្រប់ផ្នែកដូចជាផ្នែក

---

[១១] សូមអានបន្ថែម៖ https://khmercivilization.ams.com.kh/detail/២៣៨៤៩

សូរ សទ្ទតា រូបសព្ទ សម្ព័ន្ធ ន័យ ជាដើម។ ការប្រែប្រួលផ្នែកណាមួយ នឹងជះឥទ្ធិពលដល់ផ្នែកផ្សេងទៀតដែរ។

ពាក្យ «ស្ទាង» នេះ កម្លាយនិងក្លាយជាពាក្យ «ស្រវាំង» នៅសម័យទំនើបនេះមួយទៀត។ ពាក្យ «ស្រវាំង» មានន័យថាដែលភ្នឺមិនច្បាស់ព្រោះចាំងពន្លឺថ្ងៃជាដើម (ចំពោះតែភ្នែក)[១២] គឺសំដៅដល់សភាពភ្នឺប្រាល ភ្នឺខ្លាំង រហូតមើលអ្វីពុំឃើញច្បាស់ ដូចជាយើងមើលចំព្រះអាទិត្យដែលពេញពន្លឺ នាំឱ្យភ្នែកយើងក្រឡេកមើលអ្វីផ្សេងទៀតពុំច្បាស់ ឬពុំឃើញមួយរយៈ។ សភាពមើលពុំច្បាស់បែបនេះ ទោះជាមិនមើលពន្លឺភ្នឺខ្លាំង ប៉ុន្តែដោយសារភ្នែកយើងខ្សោយមើលពុំច្បាស់ ក៏យើងប្រើពាក្យ «ស្រវាំង» នេះដែរ។ សូមសង្កេតក្នុងពាក្យកម្លាយនេះ ក្នុងពាក្យឫសមានសូរ /ាង/ ឯក្នុងពាក្យកម្លាយមានសូរ /ាំង/ ទៅវិញ ប៉ុន្តែពុំកើតឡើងដោយសាររឿងកម្លាយនោះទេ គឺដោយសារការប្រែប្រួលសូរ។

ពាក្យ «ស្ទាង» នេះមានឫសមកពីពាក្យ «*វង/*វាង»[១៣] ដែលអាចមានន័យថាភ្លឺ ថ្លា មើលឃើញច្បាស់...។ ឫស «*វាង» នេះក្លាយមកជាពាក្យទំនើបថា «ភាំង»។ ក្នុងភាសាខ្មែរបុរាណ មានការវិវត្តព្យញ្ជនៈ វ > ព > ភ មានទាំងពាក្យខ្មែរបុរាណ និងបាលីសំស្ក្រឹតជាដើម ដូចពាក្យ៖ វ្រៃ > ព្រៃ, វ្រះ > ព្រះ, វិមាន > ពិមាន > ភិមាន...។ ដោយសារភាសាមានការវិវត្ត នាំពាក្យ «ភាំង» បច្ចុប្បន្ននេះ មានកម្លាយន័យច្រើន ដែលន័យខ្លះ ហាក់ឃ្លាតចាកពីន័យដើម។ តែយ៉ាងណា យើងអាចមើលឃើញន័យពាក្យ «ភាំង» ដែលអាចទាក់ទងនឹងន័យ «*វាង» ក្នុងពាក្យ «ស្ទាង» ត្រង់ថា «ភាំង» គឺមើលអ្វីមិនច្បាស់មួយភ្លែត គិតអ្វីមិនច្បាស់ មិនចេញ។

ចំណែកឯ «*វង» នេះ នៅមានប្រើមកដល់បច្ចុប្បន្នគឺ «វ៉ង់» ឬ «ហ្វង់»[14] ដែលជាឫសចូលរួមក្នុងការបង្កើតពាក្យ «ថ្វង់»។ «វ៉ង់» និង «ថ្វង់» គឺសំដៅដល់ទឹកដែលមានសភាពភ្លឺថ្លាមើលឃើញច្បាស់។ បើពិនិត្យថយក្រោយបន្តិចទៀត ពាក្យ «*វង/*វាង» នេះ

---

[១២] វចនានុក្រមខ្មែរ, ២, ១៤៧៤។

[១៣] សញ្ញា «*» នេះបញ្ជាក់ថាពុំមានវត្តមានពាក្យនេះប្រើប្រាស់ក្នុងភាសាខ្មែរបច្ចុប្បន្នទេ។ ពាក្យនេះកើតឡើងតាមរយៈការធ្វើបុនមាបនកម្ម (Reconstruction)។

[១៤] វចនានុក្រមខ្មែរ, ២, ១១៥០។

អាចមានឫសដើម (ពាក្យដើម) ជា [aŋ] (អង) ឬ [a:ŋ] (អាង) នៅក្នុងភាសាអម្បូរមនខ្មែរដទៃទៀត ដែលមានន័យថា «ពន្លឺ រះ ភ្លឺ»[១៥]។

## ៥- សន្និដ្ឋាន

ផ្អែកតាមការពិនិត្យខាងលើមក អាចវាយតម្លៃបានថាពាក្យ «ស្វាង» ជាពាក្យខ្មែរបុរាណដែលមានប្រើតាំងពីសម័យមុនអង្គរមក និងត្រូវសៀមលាវយកទៅប្រើប្រាស់។ ដូច្នេះ ពាក្យ «ស្វាង» ពុំមែនជាពាក្យមានប្រភពមកពីសៀមនោះទេ។

## បញ្ជីឯកសារ


ក្រុមប្រឹក្សាជាតិភាសាខ្មែរ. *វចនានុក្រមខ្មែរ*. ក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា. ភ្នំពេញ, ២០២២.

វចនានុក្រមខ្មែរ. ២. ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨.

ឡុងសៀម. *វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី ៦-៨)*. រោងពុម្ព ភ្នំពេញ, ២០០០.

Jenner, Philip N. *A Dictionary of Pre-Angkorian Khmer*. The Australian National University, 2009.

Saveros, Pou. *Dictionnaire vieux khmer-français-anglais. An Old Khmer-French-English Dictionary. វចនានុក្រមខ្មែរចាស់-បារាំង-អង់គ្លេស*. L'harmattan, 2004.

'SEAlang Library Lao Lexicography'. Accessed 29 November 2025. http://sealang.net/lao/dictionary.htm.

Shorto, Harry Leonard. *A Mon-Khmer Comparative Dictionary*. Edited by Paul Sidwell, Doug Linguist Cooper, and Christian Bauer. Pacific Linguistics, Research School of Pacific and Asian Studies, The Australian National University, 2006.

'พจนานุกรม ฉบับราชบัณฑิตยสถาน พ.ศ.๒๕๕๔'. Accessed 29 November 2025. https://dictionary.orst.go.th/.

ภักดีคำ, ศานติ. *พจนานุกรมคำยืมภาษาเขมรในภาษาไทย*. คณะกรรมการสมาคมวัฒนธรรมไทย–กัมพูชา กรมสารนิเทศ กระทรวงการต่างประเทศ, ๒๐๐๖.


[១៥] Harry Leonard Shorto, *A Mon-Khmer Comparative Dictionary*, ed. Paul Sidwell et al. (Pacific Linguistics, Research School of Pacific and Asian Studies, The Australian National University, 2006), 13 & 175.

អត្ថបទដោយៈ ហ៊ិន ឈុនតេង

# បញ្ជីរូបភាព




តារាងបង្ហាញអំពីឫសគល់និងកម្វាយរបស់ពាក្យ «ស្វាង»

| សិលាចារឹក | ប្រភពសិលាចារឹក |
|---|---|
|  ស្វាង៑ | K.៥៤ ប.១០ គ.ស.៦២៨/៦២៩ |
|  សិវាង៑ | K.៥០២ ប.៦ ស.វ.៧ |
|  សង៑ហ្វង៑ | K.៤៨០ ប.២ ស.វ.៧ |
|  សង៑ហ្វាង៑ | K.៥៤ ប.១០ គ.ស.៦២៨ |
|  ស្វាង | K.៣០២/IMA១៥ ប.១០ គ.ស.១៦៣១ |

តារាងបង្ហាញសំណេរពាក្យ «ស្វាង» ក្នុងសិលាចារឹក



សម្រង់ឃ្លាក្នុងសិលាចារឹកត្រពាំងប្រី K.១២៧

អត្ថបទដោយ៖ ហ៊ុន ឈុនតេង